## **សមុទ្រដែនដី** (Territorial Sea)

-សមុទ្រដែនដីលាតសន្ធឹងចេញពីខ្សែបន្ទាត់មូលដ្ឋានឆ្ពោះទៅឯនាយសមុទ្រ និងមិនហួសពី ១២ម៉ែល៍សមុទ្រ។

**មាត្រា៣នៃអនុសញ្ញា** UNCLoS **ឆ្នាំ១៩៨២៖**

រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែងទទឹងនៃសមុទ្រដែនដីរបស់ខ្លួន រហូតដល់ដែនកំណត់មួយដែលមិនលើសពីចម្ងាយ១២ម៉ាយល៍ (nautical miles) ដែលវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋានដែលបានកំណត់ដោយអនុលោមតាមអនុសញ្ញានេះ។

-រដ្ឋជាប់ឆ្នេរមានអធិបតេយ្យពេញលេញលើដែនសមុទ្ររបស់ខ្លួន។

-រដ្ឋមានអធិបតេយ្យពេញលេញ ពោលគឺមានអំណាចពេញទីក្នុងការអនុវត្តច្បាប់ជាតិ របស់ខ្លួនលើសកម្មភាពនានានៅក្នុងសមុទ្រដែនដី។ អធិបតេយ្យរបស់រដ្ឋជាប់ឆ្នេរក្នុងសមុទ្រដែនដី មានលើដីក្រោមដីនិងលើអាកាសផងដែរ។

- រដ្ឋជាប់ឆ្នេរ ត្រូវផ្សព្វផ្សាយនូវច្បាប់នាវាចររបស់ខ្លួន ឲ្យបានដឹងជាសាធារណៈ។

-ច្បាប់អន្តរជាតិផ្តល់ឱ្យនាវាបរទេសនូវសិទ្ធិឆ្លងកាត់ដោយគ្មានការបំពាន (innocent passage) និងដោយមិនធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ (UNCLoS មាត្រា១៧ )។